ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខៈ ២៣៧ ឧរថ.ចក.អប.

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៤

# អាជ្ញាប័ណ្ណស្វែងរករ៉ែ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រង និង ការធ្វើអាជីវកម្មធនធានរ៉ែ ។
- បានឃើញ អនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញកិច្ចព្រមព្រៀងស្តីពីការវិនិយោគទុនសិក្សាស្រាវជ្រាវរុករករ៉ែ នៅតំបន់ភ្នំដែក ស្រុករវៀង ខេត្តព្រះវិហារ ចុះថ្ងៃទី ២៤ ខែមិនា ឆ្នាំ ១៩៩៤ រវាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលជាមួយក្រុមហ៊ុន DELCOM CAMBODIA PTE.LTD. ។
- បានឃើញលិខិតស្នើសុំអាជ្ញាប័ណ្ណរបស់ក្រុមហ៊ុនលេខ : Re: DC/MINE/ 0056 /២០០៣ ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០០៣ នៅតំបន់ភ្នំដែក ស្រុករវៀង ខេត្តព្រះវិហារ ។

## សម្រេច

<u>ប្រការ១</u> : អនុញ្ញាតិអោយក្រុមហ៊ុន DELCOM CAMBODIA PTE.LTD. មានអាសយដ្ឋានផ្ទះលេខ ២៦ ផ្លូវលេខ ៦០៤ សង្កាត់បឹងកក់ ២ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ធ្វើការសិក្សាស្រាវជ្រាវស្វែងរករ៉ែ នៅតំបន់ភ្នំដែក ក្នុងស្រុករវៀង ខេត្តព្រះវិហារ លើផ្ទៃដីទំហំ ១៦២ គីឡូម៉ែត្រការ៉េ ដែលមានកូអរដោណេដូចខាងក្រោម និងផែនទីទីតាំងដូចមានក្នុងឧបសម្ព័ន្ធទី ៣ :

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ ទូរសារ : (៨៥៥)២៣ - ៤២៨ ២៦៣
45 Preah Norodom Boulevard . Khan Daun Penh . Phnom Penh ( Cambodia ) Tel / Fax : (855) 23 - 428 263

| ចំណុច | អាប់ស៊ីស | អ័រដោនេ | ចំណុច | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| A | 49100 | 148000 | $D_1$ | 49700 | 147000 |
| B | 50900 | 148000 | E | 49700 | 147300 |
| $C_1$ | 50900 | 147000 | F | 49100 | 147300 |

<u>ប្រការ២</u> : ក្រុមហ៊ុន **DELCOM CAMBODIA PTE.LTD.** ត្រូវដំណើរការសិក្សាស្រាវជ្រាវស្វែងរុករករ៉ែ បន្តលើផ្ទៃដីដែលបានកំណត់ខាងលើ ដោយអនុវត្តទៅតាមផែនការឆ្នាំ និងកម្មវិធីការងាររបស់ក្រុមហ៊ុន ដោយធានាអនុវត្តតាមបទដ្ឋានបច្ចេកទេសក្នុងការសិក្សាស្រាវជ្រាវស្វែងរុករករ៉ែ ។

<u>ប្រការ៣</u> : អាជ្ញាប័ណ្ណនេះមានតំលៃដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៥ ដែលជាកាលបរិច្ឆេទបញ្ចប់នៃដំណាក់ការសិក្សាស្រាវជ្រាវ ។ ក្រុមហ៊ុនត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណអាជីវកម្មធនធានរ៉ែ បន្ទាប់ពីដំណាក់ការសិក្សាស្រាវជ្រាវត្រូវបានបញ្ចប់ ក្នុងករណីលទ្ធផលនៃការសិក្សាស្រាវជ្រាវមានប្រសិទ្ធិភាពសេដ្ឋកិច្ច ។

<u>ប្រការ៤</u> : ក្នុងករណីប្រព្រឹត្តល្មើសលើលក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ១៩៩៤ អាជ្ញាប័ណ្ណនេះនឹងត្រូវព្យួរទុក ឬ ដកហូត ឬ ត្រូវពិន័យទៅតាមច្បាប់ស្តីពីការគ្រប់គ្រង និង ការធ្វើអាជីវកម្មធនធានរ៉ែ ។

<u>ប្រការ៥</u> : អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពលខេត្តព្រះវិហារ និង ប្រធានក្រុមហ៊ុន **DELCOM CAMBODIA PTE.LTD.** ត្រូវទទួលអនុវត្តអាជ្ញាប័ណ្ណនេះតាមភារៈកិច្ចរៀងៗខ្លួន ។

<u>ប្រការ៦</u> : អាជ្ញាប័ណ្ណនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ស៊ុយ_សែម

<u>ចំលងជូន</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- សាលាខេត្តព្រះវិហារ
- អភិបាលស្រុករវៀង
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ ទូរសារ (៨៥៥) ២៣-៤២៨២៦៣
#45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh (Cambodia) Tel/ Fax: (855) 23-428263